00203898

002/19-09-2007-អ.វ.ត.ក/ក.ស.ច.ស (អបជ-09)

C33/I/3

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**សំណុំរឿងលេខ:** ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ-០៩)

**ដាក់ទៅ:** អង្គបុរេជំនុំជម្រះ

**ថ្ងៃដាក់:** ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៨

**ភាគីអ្នកដាក់:** មេធាវីរបស់លោក នួន ជា

**ភាសាដើម:** អង់គ្លេស

**ប្រភេទឯកសារ:** សាធារណៈ

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 14 / 07 / 2008
ម៉ោង (Time/Heure): 15 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## បណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងទៅនឹងដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួន

**អ្នកដាក់ឯកសារ:**

**មេធាវីរបស់លោក នួន ជា**

លោកមេធាវី សុន អរុណ

លោកមេធាវី Michiel PESTMAN

លោកមេធាវី Victor KOPPE

ជំនួយការដោយ:

លោក ម៉ន ចាន់ណា

លោក Andrew IANUZZI

**អ្នកទទួលឯកសារ:**

**ចៅក្រមនៃអង្គបុរេជំនុំជម្រះ**

លោក ប្រាក់ គឹមសាន

លោក ន័យ ថុល

លោក ហួត វុទ្ធី

លោកស្រី Katinka LAHUIS

លោក Rowan DOWNING

ប៉ែន ពេជ្រសាលី

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

លោក តាន់ សេងណារ៉ុង

Anees AHMED

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 15 / 07 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

# I. សេចក្តីផ្តើម

1. អនុលោមតាមវិធាន ៧៣ ៧៤ និង ៧៥ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ហៅថា"វិធានផ្ទៃក្នុង") មេធាវីការពារក្តីរបស់ជនត្រូវចោទឈ្មោះ **នួន ជា** (ហៅថា "មេធាវីការពារ") សូមដាក់បណ្តឹងឧទ្ធរណ៍នេះនៅអង្គបុរេជំនុំជម្រះ (ហៅថា"អ.ប.ជ") ប្រឆាំងនឹងដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន (ហៅថា "ដីកា") ដែលចេញដោយការិយាល័យសហចៅក្រមស៊ើបអង្កេត (ហៅថា"ក.ស.ច.ស")[1] ។

2. ដីកានេះបញ្ជាក់ពីការដាក់នូវរបបឃុំខ្លួនឱ្យនៅដាច់ដោយឡែកពីគ្នាដោយបង្ខំ ដែលគ្មានថ្ងៃបញ្ចប់ (ហៅថា "របប") ទៅលើលោក **នួន ជា** និង ជនត្រូវចោទបួននាក់ផ្សេងទៀតដែលដាក់ឃុំនៅក្នុងមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ដោយមូលហេតុថាលក្ខខណ្ឌបែបនេះ គឺចាំបាច់ដើម្បីទប់ស្កាត់ "ការត្រូវរូវគ្នាប្រកបដោយសក្តានុពលមុនពេលជំនុំជម្រះ"[2] ។ ក.ស.ច.ស ប្រកាន់ជំហរថា ការដាក់ឃុំឱ្យនៅដាច់ដោយឡែកពីគ្នា (របប) គឺមានលក្ខណៈគ្រប់គ្រាន់ដែលត្រូវបានធ្វើយុត្តិកម្មដោយការយោងលើយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប (ហៅថា "ECHR") នៅក្នុងករណីជាក់លាក់មួយចំនួន បានជំរុញឱ្យមានការដាក់នូវវិធានការណ៍ស្រដៀងគ្នានេះ ដោយមិនតម្រូវនូវភស្តុតាងបញ្ជាក់ពីហានិភ័យនៃការឃុបឃិតគ្នាឡើយ[3] ។ ក្នុងការអនុវត្តនិយាមរបស់ ECHR ក.ស.ច.ស សម្រេចថាការដាក់ឃុំជនណាម្នាក់ឱ្យនៅដាច់ដោយឡែកពីអ្នកជាប់ឃុំដទៃទៀត មិនត្រូវបានចាត់ទុកថាជាការធ្វើបាបបែបអមនុស្សធម៌ ឬ ការប្រព្រឹត្តបែបបន្ថោកបន្ទាបឡើយ,[4] រំលោភបំពានសិទ្ធិរបស់លោក **នួន ជា** ចំពោះជីវិតឯកជន និង ជីវិតគ្រួសារ,[5] ហើយក៏មិនបានរំលោភដល់ការសន្មតជាមុនថាគ្មានទោស[6] ឬ សិទ្ធិនៅស្ងៀមមិនឆ្លើយតបផងដែរ[7] ។

3. មេធាវីការពារសូមលើកឡើងថា: (i) បណ្តឹងឧទ្ធរណ៍អាចទទួលបាន (ii) គោលការណ៍ប្រកាន់តាមអ្វីដែលបានសម្រេចកន្លងមក (Stare decisis) ត្រូវអនុវត្តនៅដំណាក់កាលអង្គបុរេជំនុំជម្រះ

---

[1] ឯកសារលេខ A-169/II ចុះថ្ងៃទី២១ ខែឧសភា ២០០៨ ។ ដីកានេះបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ជាឯកសារលេខ Nos. A-104/V, A-166/III និង C-33 ។

[2] ដីកា កថាខណ្ឌទី៥ ។

[3] ដីកា កថាខណ្ឌទី១ ដល់ទី៦ ។

[4] ដីកា កថាខណ្ឌទី៤ ដល់ទី៩ ។

[5] ដីកា កថាខណ្ឌទី១ ដល់ទី១១ ។

[6] ដីកា កថាខណ្ឌទី១២ ។

[7] ដីកា កថាខណ្ឌទី ១៣ ។

នៅ អ.វ.ត.ក អនុលោមតាមយុត្តិសាស្ត្រដែលបង្កើតឡើងដោយអង្គបុរេជំនុំជម្រះនេះ ការដាក់ឃុំឲ្យនៅដាច់ដោយឡែកពីគ្នា គឺ(iii)មិនចាំបាច់ ហើយ(iv)ក៏មិនមានសមាមាត្រចំពោះផលប្រយោជន៍នៃការស៊ើបអង្កេតដែរ និង(v) ច្បាប់ករណីរបស់តុលាការអឺរ៉ុបសិទ្ធិមនុស្សដែលដីកាបានពឹងអាស្រ័យនោះ គឺពាក់ព័ន្ធតិចតួចជាមួយករណីនេះ ។

## II. **អង្គហេតុពាក់ព័ន្ធ**

4. លោក **នួន ជា** ត្រូវបានចាប់ខ្លួន និង ឃុំខ្លួនបណ្ដោះអាសន្នដោយអាជ្ញាធរនៃអង្គជំនុំជម្រះវិសាមញ្ញនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧[8] ។ ខណៈដែលគ្មានឯកសារផ្លូវការរបស់ អ.វ.ត.ក មុនដីកាសម្រេចសួរដេញដោល ដែលដោះស្រាយចំពោះលក្ខខណ្ឌជាក់លាក់នៃការឃុំខ្លួនបណ្ដោះអាសន្នលោក **នួន ជា** ការដាក់ឃុំឲ្យនៅដាច់ដោយឡែកពីគ្នា- ដែលដាក់កម្រិតការទំនាក់ទំនងទាំងអស់រវាងលោក **នួន ជា** ជាមួយអ្នកជាប់ឃុំបួននាក់ដទៃទៀត- ត្រូវបានអនុវត្តដោយអាជ្ញាធររបស់អង្គជំនុំជម្រះវិសាមញ្ញអស់រយៈពេលជាងដប់(១០)ខែកន្លងមកហើយ[9] ។

5. មេធាវីការពារបានដាក់ "សំណើសុំកែប្រែលក្ខខណ្ឌនៃការឃុំខ្លួន" របស់ខ្លួននៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៨[10] ។ ខណៈដែលសំណើនោះមិនទាន់ត្រូវបានដោះស្រាយនៅឡើយ អង្គជំនុំជម្រះនេះបានចេញ"សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ទាក់ទងទៅនឹងការប្រាស្រ័យទាក់ទងរវាងជនត្រូវចោទម្នាក់នឹងប្រពន្ធរបស់គាត់" (ហៅថា "សេចក្ដីសម្រេចអៀង") ដែល(i) បង្កើតគោលការណ៍ទូទៅ

---

[8] ឯកសារ No. C-7/, កំណត់ហេតុនាំជនសង្ស័យ និងឯកសារ C-9 "ដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្ន ។ អង្គជំនុំជម្រះបានសម្រេចតម្កល់ដីកាឃុំខ្លួនបណ្ដោះអាសន្ននៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ ។ ឯកសារលេខ No. C-11/54 "សាលដីកាទៅលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទ នួន ជា ។

[9] មេធាវីការពារទើបតែបានដឹងអំពីអត្ថិភាពនៃការសម្រេចឃុំខ្លួនឲ្យនៅដាច់ដោយឡែកពីគ្នានេះ (របប) នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៨ (បួន(៤) បន្ទាប់ការចាប់ខ្លួនលោក នួន ជា) តាមរយៈការឆ្លើយតបរបស់ ក.ស.ច.ស ទៅលើសំណើរបស់ អៀង សារី ស្នើសុំការអនុញ្ញាតឲ្យជួបប្រពន្ធរបស់គាត់ ។ នៅក្នុងការបដិសេធសំណើនេះ ក.ស.ច.ស បានលើកឡើងថា "យើងពុំមានផែនការផ្លាស់ប្ដូលក្ខខណ្ឌដែលកំពុងអនុវត្តចំពោះការសួរសុខទុកគ្នានេះទេ" ។ ឯកសារ No. 104/I, ចុះនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៨ ។ ការិយាល័យចៅក្រមស៊ើបអង្កេតមិនបានបញ្ជាក់ថាតើលក្ខខណ្ឌនោះជាអ្វី តើដាក់លក្ខខណ្ឌនោះនៅពេលណា ហើយនរណាចេញលក្ខខណ្ឌនោះ ហើយតើឯកសារផ្លូវការរបស់ អ.វ.ត.ក មួយណាអាចរកបាន ។

[10] ឯកសារលេខ A-169 (ដែលស្វែងរកការធ្វើយុត្តិកម្មលើអំណាចរបស់ ក.ស.ច.ស ដើម្បីដាក់លក្ខខណ្ឌនៃការឃុំខ្លួនថាជាបញ្ហាទូទៅ ដោយបង្កើតឡើងនូវដីកាជាក់លាក់មួយដើម្បីបង្គាប់ឲ្យមានការឃុំខ្លួនឲ្យនៅដាច់ដោយឡែកពីគ្នា និង មោឃភាពដីកាបែបនេះទៅលើអ្វីដែលបានកើតឡើង) ។

សម្រាប់គ្រប់គ្រងលក្ខខណ្ឌនៃការឃុំខ្លួននៅអង្គជំនុំជម្រះវិសាមញ្ញ និង(ii) ផ្លាស់ប្តូរការឃុំខ្លួនឱ្យនៅដាច់ដោយឡែកពីគ្នា ដោយអនុញ្ញាតឱ្យ អៀង ធីរិទ្ធនិងអៀង សារី "ដើម្បីជួបប្រាស្រ័យទាក់ទងគ្នាស្របតាមវិធាននៃការឃុំខ្លួនដែលអនុវត្តនៅមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក"[11] ។

6. ទាក់ទិនទៅនឹងសេចក្តីសម្រេចរបស់ អៀង មេធាវីការពារបានសរសេរលិខិតទៅ ក.ស.ច.ស នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០០៨ ស្នើសុំ "ការធានា [...] ថាដីកាសម្រេចឱ្យឃុំខ្លួនឱ្យនៅដាច់ដោយឡែកពីគ្នាណាមួយរបស់ ក.ស.ច.ស ដែលពាក់ព័ន្ធជាពិសេសជាមួយលោក នួន ជា [...] ត្រូវបានទុកជាមោឃៈភាពផងដែរ"[12] ។ មេធាវីការពារទទួលចម្លើយតបនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ នៅពេលការិយាល័យចៅក្រមស៊ើបអង្កេតផ្តល់ការធ្វើយុត្តិកម្មចុងក្រោយរបស់ខ្លួនសម្រាប់ការដាក់ឃុំឱ្យនៅដាច់ដោយឡែកពីគ្នា[13] ។

## III. ច្បាប់នៅជាធរមាន

### ក. យុត្តាធិការរបស់អង្គបុរេជំនុំជម្រះ

7. វិធាន ៧៣ ផ្តល់អំណាចឱ្យអង្គជំនុំជម្រះនេះនូវ "យុត្តាធិការផ្តាច់មុខលើ [...] បណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដូចមានចែងនៅក្នុងវិធាន ៧៤" ។ អនុលោមតាមវិធាន ៧៤(៣)(ច) ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាណាមួយរបស់សហចៅក្រមស៊ើបអង្កេត "ទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន ឬ ដីកាសម្រេចឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ" ។

### ខ. អនុភាពនៃសាលដីកាពីមុន

8. អនុលោមតាមទ្រឹស្តីប្រកាន់តាមអ្វីដែលបានសម្រេចកន្លងមក (Stare dicisis) នៅពេលតុលាការមួយដាក់ចេញនូវគោលការណ៍ច្បាប់ចំពោះអង្គហេតុជាក់លាក់មួយ តុលាការនេះនឹងប្រតិបត្តិតាមគោលការណ៍នោះ ហើយអនុវត្តទៅលើករណីក្រោយៗទាំងអស់នៅពេលមានអង្គហេតុដូចគ្នា ។ បន្ថែមពីលើនេះ នៅពេលគោលការណ៍នេះត្រូវបានប្រកាសដោយតុលាការជាន់ខ្ពស់ នោះតុលាការ

---

[11] ឯកសារ A-104/II7 ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ ទំព័រ៦។

[12] ឯកសារ A-104/I ។

[13] សូមមើលដីកា កថាខណ្ឌទី៤ និងទី៥ ។

ជាន់ទាបដែលស្ថិតនៅក្រោមយុត្តាធិការដូចគ្នា ត្រូវប្រតិបត្តិតាមយុត្តិសាស្ត្រដែលបានបង្កើត ។ " គោលការណ៍ Stare dicisis គឺជាគោលនយោបាយផ្នែកតុលាការ ដោយផ្អែកលើគោលការណ៍នោះ នៅពេលគ្មានអំណាចនៃការជំទាស់ នោះករណីត្រូវតែបានសម្រេចដើម្បីថែរក្សាស្ថេរភាព និង និរន្តភាពនៃការអនុវត្តច្បាប់ ។ទ្រឹស្តី គឺជាមធ្យោបាយដែលតុលាការធានាថាច្បាប់នឹងមិនត្រូវបានកែប្រែដោយងាយៗពេកទេ តែនឹងត្រូវបានអភិវឌ្ឍដោយផ្អែកលើគោលការណ៍មួយដែលងាយយល់[14] ។

9. តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ហៅថា "ICTY" ) បានពិចារណាជាយូរមកហើយថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ចងកាតព្វកិច្ចទៅលើអង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY[15] ។ មុននឹងការឈានដល់ការចេញសេចក្តីសម្រេចនេះ ការយកចិត្តទុកដាក់ពិសេសត្រូវបានផ្តោតទៅលើការអនុវត្តជាក់ស្តែង ទាំងក្នុងយុត្តាធិការច្បាប់កុំម៉ុងឡូ (common law) និងទាំងក្នុងយុត្តាធិការច្បាប់ស៊ីវិល (civil law):

> ជាទូទៅ នៅក្នុងយុត្តាធិការច្បាប់កុំម៉ុងឡូ (common law) សេចក្តីសម្រេចរបស់តុលាការជាន់ខ្ពស់ចងកាតព្វកិច្ចទៅលើតុលាការជាន់ទាប ។ នៅក្នុងយុត្តាធិការច្បាប់ស៊ីវិល (civil law) ពុំមានទ្រឹស្តីយុត្តិសាស្ត្រដែលចងកាតព្វកិច្ចនោះទេ ។ ប៉ុន្តែ តាមការអនុវត្តជាក់ស្តែង តុលាការជាន់ទាបជាច្រើនហាក់ដូចជាអនុវត្តតាមសេចក្តីសម្រេចរបស់តុលាការជាន់ខ្ពស់ ។ ដូចអ្នកធ្វើបទអត្ថាធិប្បាយមួយរូបបានលើកឡើងថា: "វាពិបាកនឹងបំផ្លើសដើម្បីនិយាយថា *ទ្រឹស្តីនៃការប្រកាន់យកតាមអ្វីដែលបានសម្រេចរួចមកហើយ (stare decisis)* នៅក្នុងច្បាប់កុំម៉ុងឡូ និងការអនុវត្តរបស់តុលាការអនុវត្តប្រព័ន្ធច្បាប់ស៊ីវិល ជាទូទៅនាំឱ្យមានលទ្ធផលដូចគ្នាណាស់[...]។ តាមពិតនៅពេលចៅក្រមមួយរូប អាចស្វែងរកឃើញសេចក្តីសម្រេចមួយ ឬច្រើនរបស់តុលាការកំពូលដែលជាវិធានដែលចៅក្រមយល់ថា ពាក់ព័ន្ធដល់សេចក្តីសម្រេចលើរឿងក្តីនៅចំពោះមុខគាត់ *នោះចៅក្រមរូបនេះនឹងអនុវត្តតាមសេចក្តីសម្រេចទាំងនោះ ហើយវិធានដែលមាននៅក្នុងសេចក្តីសម្រេចទាំងនោះមានច្រើន ដូចជានៅក្នុងប្រទេសអាឡឺម៉ង់ ក៏ដូចប្រទេសអង់គ្លេស ឬប្រទេសបារាំងផងដែរ*"[16]

---

[14] យុត្តិសាស្ត្រអាមេរិកាំង 2d Ed (2007) 20 Am Jur 2d Court 129.

[15] សូមមើលរឿងក្តីរវាង *រដ្ឋអាជ្ញា តទល់នឹង Aleksovski* សំណុំរឿងលេខ IT-95-14/1-A "សាលក្រម" ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០០ (ហៅថា "សាលក្រម Aleksovski")។

[16] សាលក្រម Aleksovski កថាខ័ណ្ឌ ១១២ (ដកស្រង់សំដី Zweigert និង Kotz សេចក្តីផ្តើមទៅនឹងច្បាប់ប្រៀបធៀប (Comparative Law) (1998) ទំព័រ ២៦៣)។ សូមមើលចំនុចដូចគ្នានេះផងដែរ កថាខ័ណ្ឌ ៩៧ (មានបន្ថែមសេចក្តីបញ្ជាក់) (អង្គជំនុំជម្រះសាលាឧទ្ធរណ៍ទទួលស្គាល់ថា គោលគារណ៍ដែលចង្អុលបង្ហាញពីនិន្នាការទូទៅ ទាំងក្នុងប្រព័ន្ធច្បាប់កុំមិនឡូ និងទាំងក្នុងប្រព័ន្ធច្បាប់ស៊ីវិល ទោះបីជាបញ្ហានៃទ្រឹស្តីក្តី ឬបញ្ហានៃការអនុវត្តក្តី ដែលតុលាការជាន់ខ្ពស់នានា តាមធម្មតា នឹង

អង្គជំនុំជម្រះសាលាឧទ្ធរណ៍ពិចារណាថា ការតាក់តែងលក្ខន្តិកៈមួយឱ្យបានត្រឹមត្រូវតម្រូវថា មូលហេតុនៃការចេញសេចក្ដីសម្រេចរបស់ខ្លួន គឺចងភ្ជាប់កាតព្វកិច្ចទៅលើអង្គជំនុំជម្រះសាលាដំបូងនូវមូលហេតុដូចខាងក្រោមនេះ:

(i) លក្ខន្តិកៈបង្កើតនូវរចនាសម្ព័ន្ធតាមឋានានុក្រម ដែលក្នុងនោះអង្គជំនុំជម្រះសាលាឧទ្ធរណ៍ត្រូវបានផ្ដល់មុខងារក្នុងការដោះស្រាយបញ្ហាអង្គហេតុ និងអង្គច្បាប់ដែលកើតចេញពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងឱ្យបានច្បាស់លាស់ [...] ហើយសេចក្ដីសម្រេចរបស់ខ្លួនគឺជាសេចក្ដីសម្រេចជាចុងក្រោយបិទផ្លូវតវ៉ា។

(ii) បេសកកម្មចំបងរបស់តុលាការនេះ គឺដើម្បីធ្វើការផ្ដន្ទាទោសជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះការរំលោភបំពានធ្ងន់ធ្ងរនៃច្បាប់មនុស្សធម៌អន្តរជាតិ មិនអាចសម្រេចទៅបានទេ ប្រសិនបើជនជាប់ចោទ និងអយ្យការមិនមានការធានាពីភាពច្បាស់លាស់ និងភាពអាចព្យាករបាន នៅក្នុងការអនុវត្តច្បាប់ជាធរមានបានទេ និង

(iii) ដូចដែលអង្គជំនុំជម្រះបានលើកឡើងពីមុនរួចមកហើយ សិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍គឺជាធាតុមួយនៃលក្ខខណ្ឌធានាឱ្យមានសវនាការមួយប្រកបដោយយុត្តិធម៌ ដែលសិទ្ធិនេះផ្ទាល់គឺជាវិធាននៃច្បាប់ប្រពៃណីអន្តរជាតិ និងផ្ដល់ឱ្យមានការលើកស្ទួយដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការប្រព្រឹត្តមកលើរឿងក្ដីបែបនេះឱ្យបានដូចៗគ្នា។ [...] [17]។

10. ក្នុងការអនុវត្តជាក់ស្ដែង ជាទម្លាប់ តុលាការកម្ពុជាអនុវត្តគោលការណ៍នៃការប្រកាន់យកតាមអ្វីដែលបានសម្រេចរួចមកហើយចំពោះសាលាឧទ្ធរណ៍។

## គ. ការជាក់កម្រិតចំពោះការទាក់ទងគ្នាក្នុងចំណោមជនត្រូវចោទ

---

អនុវត្តតាមសេចក្ដីសម្រេចមុនៗរបស់ខ្លួន ហើយនឹងមិនយកតាមសេចក្ដីសម្រេចទាំងនោះ តែក្នុងករណីលើកលែង តែប៉ុណ្ណោះ គឺតម្រូវការចំពោះភាពស៊ីសង្វាក់គ្នា ភាពច្បាស់លាស់ និងភាពអាចព្យាករបាន។ និន្នាការនេះក៏អាចមើលឃើញនៅក្នុងតុលាការអន្តរជាតិ។ ចៅក្រម Shahabuddeen កត់សម្គាល់ឃើញថា: "បំណងប្រាថ្នានៃភាពស៊ីសង្វាក់គ្នា ភាពច្បាស់លាស់ និងភាពអាចព្យាករបាន ដែលគាំទ្រប្រព័ន្ធច្បាប់មួយដែលមានលក្ខណៈ ទទួលខុសត្រូវ លើកឡើងថា តុលាការមិនគួរអនុវត្តអំណាចរបស់ខ្លួនដោយឯកចេញ ពីសេចក្ដីសម្រេចមុនៗនោះឡើយ លើកលែងតែក្នុងករណីដែលបានដឹងគ្រប់ជ្រុងជ្រោយ [...]។ អាស្រ័យហេតុនេះ តុលាការត្រូវអនុវត្ត តាមគោលនយោបាយតុលាការ ដោយមិនត្រូវធ្វើឱ្យអំណាចនៃសេចក្ដីសម្រេចរបស់ខ្លួនចុះអន់ថយដោយមិនចាំបាច់នោះទេ"។) (ដកស្រង់សំដីរបស់ Shahabuddeen យុត្តិសាស្ត្រនៅក្នុងតុលាការពិភពលោក (World Court) ឆ្នាំ១៩៩៦ ទំព័រ ២៣៩)។

[17] សាលក្រម Aleksovski កថាខ័ណ្ឌ ១១៣ ។

11. នៅក្នុងសេចក្តីសម្រេច អៀង បញ្ជាក់ពីអំណាចរបស់ ក.ស.ច.ស ក្នុងការដាក់កម្រិតទៅលើការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមករវាង និងក្នុងចំណោមជនត្រូវចោទដែលឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក "ដើម្បីផលប្រយោជន៍នៃការស៊ើបអង្កេត"[18]។ ក្នុងការអនុវត្តអំណាចបែបនេះ ក.ស.ច.ស ត្រូវបានតម្រូវឲ្យថ្លឹងថ្លែងពីផលប្រយោជន៍នៃការស៊ើបអង្កេតដែលត្រូវប៉ាន់ប្រមាណទល់នឹងសិទ្ធិរបស់ជនត្រូវចោទៈ ខណៈដែល "វិធាន ៥៥(៥) មានភាពទូលំទូលាយគ្រប់គ្រាន់នៅក្នុងវិសាលភាពរបស់វាក្នុងការផ្តល់ [ក.ស.ច.ស] នូវយុត្តាធិការដើម្បីកម្រិតការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមករវាងជនត្រូវចោទ និងមនុស្សផ្សេងទៀត"[19] ដែលយុត្តាធិការបែបនេះត្រូវបាន "កម្រិតដោយវិធានផ្ទៃក្នុង ២១(២)"[20] ដែលតម្រូវថា "វិធានការចាប់បង្ខំទាំងឡាយណាដែលអាចប្រឈមមុខចំពោះ [ជនត្រូវចោទ] [...] ត្រូវតែកម្រិតតឹងរ៉ឹងបំផុតសម្រាប់តែតម្រូវការនៃដំណើរការនីតិវិធី ដោយសមាមាត្រទៅនឹងកម្រិតធ្ងន់ធ្ងរនៃបទល្មើសដែលចោទប្រកាន់ និងដោយគោរពសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិឲ្យបានពេញលេញ"។ បន្ថែមលើនេះទៅទៀត សេចក្តីសម្រេចនេះបានលើកឡើងថា ការដាក់កម្រិតចំពោះការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ត្រូវតែចេញដោយសេចក្តីសម្រេចមួយមានហេតុផល"[21] ដោយបង្ហាញឲ្យឃើញថា "ផលប្រយោជន៍

---

[18] សេចក្តីសម្រេច អៀង កថាខ័ណ្ឌ ១៤ ។

[19] ឯកសារលេខ A-104/II/7 "សេចក្តីសម្រេចទៅលើបណ្តឹងឧទ្ធរណ៍ទាក់ទិននឹងការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមករវាងជនត្រូវចោទ និងប្រពន្ធរបស់គាត់" ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ (ហៅថា "សេចក្តីសម្រេច អៀង") កថាខ័ណ្ឌ ១៤។ ចំណាំ: វិធានផ្ទៃក្នុង ៥៥(៥) ចែងលក្ខលក្ខណៈសមហេតុផលថា: "ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត [...]។ ចុងក្រោយ សហចៅក្រមស៊ើបអង្កេតអាចៈ [...] ចាត់វិធានការសមស្របដើម្បី ផ្តល់សុវត្ថិភាព និងគាំទ្រដល់សាក្សីសំខាន់ៗ និងប្រភពដទៃទៀត [...] និង (ឃ) តាមការចាំបាច់ចេញដីកានានាដោះម្បីបំពេញកិច្ចស៊ើបសួរ ដូចជាដីកាបង្គាប់ឲ្យចូលខ្លួន ដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យឃុំខ្លួន និងដីកាបង្គាប់ឲ្យចាប់ខ្លួន"។ ក្នុងស្មារតីនេះ អ.ប.ជ បានទទួលស្គាល់ការអនុវត្តជាក់ស្តែងនៅតុលាការអន្តរជាតិផ្សេងៗដែលបានផ្តល់អំណាចតាមផ្លូវតុលាការរបស់ខ្លួនជាមួយ នឹងយុត្តាធិការកំហិត"ការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមករវាងជនត្រូវចោទ និងមនុស្សផ្សេងទៀត ដើម្បីជៀសវាងការធ្វើឲ្យ ខូចខាតដល់លទ្ធផលនៃកិច្ចដំណើរការនីតិវិធី"។ សេចក្តីសម្រេច អៀង កថាខ័ណ្ឌ ១៦ (ការទាញសំអាងហេតុ *រដ្ឋអាជ្ញា តទល់នឹង* *Katanga* *និង* *Chui* សំណុំរឿងលេខ ICC-01/04-01/07 "សេចក្តីសម្រេចលុបចោលការហាមឃាត់ការប្រាស្រ័យទាក់ទងគ្នាទៅ វិញទៅមករវាង Germain Katanga និង Mathieu Ngudjolo Chui" ដោយចៅក្រម Sylvia Steiner ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៨ (ហៅថា "សេចក្តីសម្រេច Katanga" ទំព័រ ៨) ។

[20] សេចក្តីសម្រេច អៀង កថាខ័ណ្ឌ ១៥។

[21] សេចក្តីសម្រេច អៀង កថាខ័ណ្ឌ ១៧។

មួយណាដែលត្រូវការពារ"នោះ[22] និងដោយការពន្យល់ "ថាតើកម្រិតទំនាក់ទំនងនេះជាវិធានការចាំបាច់ និងមានសមាមាត្រទៅនឹងការការពារផលប្រយោជន៍នោះដោយរបៀបណា"[23]។ សេចក្ដីសម្រេចបែបនេះមិនត្រូវចេញជាលទ្ធផលដោយ "ការឃុំឃាំងជនជាប់ឃុំ[24]ឲ្យនៅដាច់ដោយឡែកពីគ្នាតាមព្រឹត្តិហេតុនោះឡើយ"។ គោលការណ៍ទាំងនេះ គឺស្របទៅនឹងការធានាជាមូលដ្ឋានដែលចែងក្នុងកតិកាសញ្ញាអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស (ហៅថា "កតិកាសញ្ញាអឺរ៉ុប"[25]។

12. នៅក្នុងសេចក្ដីសម្រេច អៀង អង្គបុរេជំនុំជម្រះបានសម្រេចភ្លាមៗថា លក្ខខណ្ឌដែលបានលើកឡើងខាងលើ មិនត្រូវបានឆ្លើយតបនោះឡើយ ។ ជាពិសេស អង្គបុរេជំនុំជម្រះបានលើកឡើងថា ក.ស.ច.ស ខកខានមិនបានពន្យល់ឲ្យបានគ្រប់គ្រាន់"ថាតើការកម្រិតទំនាក់ទំនងរវាងជនត្រូវចោទទាំងពីរ វាផ្ដល់ការការពារដល់ផលប្រយោជន៍នៃកិច្ចស៊ើបសួរយ៉ាងដូចម្ដេចដែរនោះ"[26] ដោយសារថាតែពេលវេលាបានកន្លងផុតជាង៣០ ឆ្នាំកន្លងទៅ បានធ្វើឲ្យលោក អៀង សារី និងអ្នកស្រី អៀង ធីរិទ្ធ មានពេលវេលាគ្រប់គ្រាន់ដើម្បីពិភាក្សាអំពីបញ្ហាទាំងឡាយដែលពាក់ព័ន្ធទៅនឹងការស៊ើប

---

[22] សេចក្ដីសម្រេច អៀង កថាខ័ណ្ឌ ១៧។

[23] សេចក្ដីសម្រេច អៀង កថាខ័ណ្ឌ ១៨។ សូមមើលផងដែរ សេចក្ដីសម្រេច Katanga ទំព័រ ៩ (ការដាក់កំហិតទៅលើការប្រាស្រ័យទាក់ទងគ្នាអាចអនុញ្ញាតបានតែក្នុងករណីដែលការដាក់កំហិតទាំងនោះឆ្លើយតបចំពោះតម្រូវការនៃភាពចាំបាច់ និងមានសមាមាត្រ)។

[24] សេចក្ដីសម្រេច អៀង កថាខ័ណ្ឌ ១៨ (ការលើកឡើងពីសេចក្ដីសម្រេច Katanga ទំព័រ ៨ ដល់ ៩ ដែល តុលាការរិះគន់ ពីប្រសិទ្ធិភាពនៃសំណើចោទប្រកាន់ដែល "នាំឲ្យឈានដល់ការឃុំឃាំង Mathieu Ngudjolo Chui ដាច់ដោយឡែកពីអ្នកផ្សេងទៀត រួមទាំង Germain Katanga ដែលកំពុងត្រូវបានឃុំខ្លួននៅឯមន្ទីរឃុំឃាំង")។

[25] ទាក់ទងទៅនឹងមាត្រា ៣ នៃកតិកាសញ្ញាអឺរ៉ុប ដែលដាក់កំហិតការហាមឃាត់តឹងរ៉ឹងចំពោះទារុណកម្ម ការប្រព្រឹត្តដោយអមនុស្សធម៌ ឬដោយបន្ទាបបន្ថោកមកលើអ្នកជាប់ឃុំឃាំង។ តុលាការសិទ្ធិមនុស្សអឺរ៉ុប (ហៅកាត់ថា "ECHR") បានសម្រេចថា "គួរមានការយកចិត្តដាក់ពិសេសចំពោះការឃុំឃាំង ភាពតឹងរ៉ឹងរបស់ពួកគេ អំឡុងពេលទិសដៅដែលស្វែងរក និងប្រសិទ្ធិភាពនៃការឃុំឃាំងទៅលើបុគ្គលដែលពាក់ព័ន្ធ"។ "ត្រូវតែមានតុល្យភាពរវាងតម្រូវការនៃវិធានការ និងប្រសិទ្ធិភាព [...] ទៅលើជនជាប់ឃុំឃាំង" ហើយ "ជាពិសេស ការឃុំឃាំងឲ្យនៅតែម្នាក់ឯងមិនមែនជាការប្រាថ្នាចង់ បាននោះទេ នៅពេលដែលជនរូបនោះត្រូវ បានឃុំឃាំងរង់ចាំចំណាត់ការនីតិវិធីបន្ត។ Jessica Simor និង Ben Emmerson QC, ការអនុវត្តសិទ្ធិមនុស្ស (Sweet & Maxwell 2006), §§ 3.038, 3.040, 3.041 ។ ដោយអនុវត្តតាមមាត្រា ៨ នៃកតិកាសញ្ញាអឺរ៉ុបដែលចែងពីសិទ្ធិគោរពដល់ជីវិត ឯកជន និងជីវិតគ្រួសារ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានលើកឡើងថា "ទោះជាយ៉ាងណាក៏ដោយ ក្នុងស្ថានភាពដែលមិនឈានដល់កម្រិតនៃភាពធ្ងន់ធ្ងរចាំបាច់សម្រាប់ការរំលោភលើមាត្រា ៣ នោះស្ថាណភាពទាំងនោះបង្កើតបានជាការរំលោភទៅលើសិទ្ធិដើម្បី គោរពដល់ជីវិតឯកជន"។ ដូចគ្នា *Ibid.*, § 8.019. ។

[26] សេចក្ដីសម្រេច អៀង កថាខ័ណ្ឌ ២០ ។

អង្កេតដែលកំពុងតែបន្ត[27]។ ហើយសេចក្តីសម្រេចនោះបានលើកឡើងបន្ថែមទៀតថា "អំឡុងពេលនៃវិធានការដ៏យូរបែបនេះ ដែលបានដាក់កំណត់តាំងពីកិច្ចស៊ើបសួរចាប់ផ្តើមនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ដោយមិនបានផ្តល់យុត្តិកម្មឲ្យបានសមស្រប បានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការប្រព្រឹត្តមកលើខ្លួនដោយមនុស្សធម៌។ ហេតុដូច្នេះ វិធានការនេះត្រូវតែបញ្ឈប់ជាដាច់ខាត"[28]។

13 នៅក្នុងសេចក្តីសម្រេចលើករណី Katanga ដែលអង្គជំនុំជម្រះនេះបានសំអាង តុលាការព្រហ្មទណ្ឌអន្តរជាតិ (ហៅថា "ICC") បានលើកឡើងថា ការដាក់កម្រិតក្នុងការប្រាស្រ័យទាក់ទងគ្នា ជាសកម្មភាពទប់ស្កាត់"ស្ថានភាពសុទ្ធសាធនោះ" គឺមិនអាចទទួលយកបានឡើយ ក្រៅពីការឃុបឃិត និង/ឬ ការជ្រៀតជ្រែកដោយមិនសមស្របទៅលើលទ្ធផលនៃដំណើរការនីតិវិធីនោះ ត្រូវតែផ្តល់យុត្តិកម្មដោយភ្ជាប់ជាមួយនូវ"ភស្តុតាងរឹងមាំ"[29]។ មួយផ្នែក សេចក្តីសម្រេចបានពឹងផ្អែកលើយុត្តាធិការប្រហាក់ប្រហែលរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ហៅថា "ICTY") និង តុលាការព្រហ្មទណ្ឌអន្តរជាតិរ៉ាវ៉ាន់ដា (ហៅថា "ICTR")[30]។ ដោយមានលើកលែងតែករណីមួយប៉ុណ្ណោះ"តុលាការព្រហ្មទណ្ឌអន្តរជាតិទាំងពីរនេះបានដាក់កម្រិតការប្រាស្រ័យទាក់ទងគ្នារវាងជនជាប់ឃុំ "ជាមួយពិភពលោកខាងក្រៅតែប៉ុណ្ណោះ ហើយមិនបានដាក់កម្រិតការប្រាស្រ័យទាក់ទងគ្នារវាងជនជាប់ឃុំ ជាមួយនឹងជនជាប់ឃុំផ្សេងទៀតនោះឡើយ (ហើយដាក់កម្រិតតិចតួចរវាងបុគ្គលដែលត្រូវចោទប្រកាន់រួមគ្នា) ។ ទោះបីការដាក់កម្រិតទាំងនេះបង្កឡើយ

---

27 សេចក្តីសម្រេច អៀង កថាខ័ណ្ឌ ១៩ ។

28 សេចក្តីសម្រេច អៀង កថាខ័ណ្ឌ ២១ (កត់សំគាល់ឃើញថា លោក អៀង សារី និងអ្នកស្រី អៀង ធីរិទ្ធ "គួរត្រូវបានអនុញ្ញាតឲ្យជួបគ្នា ស្របតាមវិធានឃុំឃាំងដែលអនុវត្តនៅមន្ទីរឃុំឃាំងខ្លួនបណ្តោះអាសន្នរបស់ អ.វ.ត.ក")។

29 សេចក្តីសម្រេចករណី Katanga ទំព័រ ១០។

30 សេចក្តីករណី Katanga ទំព័រ ១១។

ដោយ "ការរំលោភបំពានស្តែងៗទៅលើរបបឃុំខ្លួននាពេលនោះ" ដោយអ្នកជាប់ឃុំក៏ដោយ[31] ។ ក្នុងស្មារតីនេះវិធីរបស់ ICC គឺហួសពីការធានាជាអប្បរមាដែលមានចែងក្នុងកតិកាសញ្ញាអឺរ៉ុប[32]។

## IV. ឧឡឹករណ៍

### A. បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន

14 ដោយហេតុថា ដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួនពិតជា "ទាក់ទងទៅនឹងការឃុំខ្លួនបណ្តោះអាសន្ន នោះបណ្តឹងឧទ្ធរណ៍ជាប្រញាប់នេះអាចទទួលយកបាន ស្របតាមវិធានផ្ទៃក្នុង ៧៤(៣)(ច)[33]។

### B. គោលការណ៍នៃការប្រកាន់យកតាមអ្វីដែលបានសម្រេចរួចមកហើយគួរអនុវត្តចំពោះដំណើរការនីតិវិធីមុនការកាត់សេចក្តីនៅក្នុង អ.វ.ត.ក

15. សម្រាប់ហេតុផលដូចគ្នា ដែលបានបង្ហាញយ៉ាងច្បាស់ដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់ ICTY នៅក្នុងសាលដីកា Aleksovski[34] គោលការណ៍នៃ*ការប្រកាន់យកតាមអ្វីដែលបានសម្រេចរួច* គួរយកមកអនុវត្តចំពោះដំណើរការនីតិវិធីមុនការកាត់សេចក្តីនៅក្នុង អ.វ.ត.ក ។ ទីមួយ វិធានផ្ទៃក្នុងបង្កើតនូវរចនាសម្ព័ន្ធតាមឋានានុក្រម ដែល អ.ប.ជ ក្នុងចំណោមភារកិច្ចជា

---

[31] ឯកសារលេខ No. A-104/II/6, "ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងឧទ្ធរណ៍របស់របស់ អៀង សារី ទាក់ទងនឹងសិទ្ធិជួបប្រាស្រ័យទាក់ទងគ្នា កថាខណ្ឌ ១១ ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០០៨ (បញ្ជាក់បន្ថែម) (សំអាងសេចក្តីសម្រេចករណី Katanga ទំព័រ១១) ។ កំណត់សំគាល់: អញ្ញត្រកម្មកើតឡើងនៅក្នុងករណី*ព្រះរាជអាជ្ញា តទល់ជាមួយ Delalic et al* ដែល ICTY ហាមការប្រាស្រ័យទាក់ទងគ្នារវាងសហជនជាប់ឃុំ ដោយសារពួកគេផ្លាស់ប្តូរកំណត់ត្រា ដោយលាក់កំណត់ត្រានៅកន្លែងដែលពួកគេទាំងពីរអាចរកឃើញបាន ក្នុងគោលបំណងបញ្ចៀសការតាមដាន ឬ ត្រួតពិនិត្យដោយមន្ត្រីពន្ធនាគាររបស់ ICTY " សេចក្តីសម្រេចករណី Katanga ទំព័រ ១១)។

[32] សូមមើលកថាខណ្ឌទី២៣ ដល់ទី២៤ ខាងក្រោម ។

[33] បណ្តឹងឧទ្ធរណ៍នេះបានដាក់ទាន់ពេលវេលា។ *សូមមើល* ឯកសារលេខ C-33/I/2 អ.ប.ជ "សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពន្យារពេលដើម្បីដាក់បណ្តឹង- បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួន ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០០៨ (ដែលផ្តល់ការយល់ព្រមទៅនឹងសំណើរបស់មេធាវីការពារក្តីសុំពន្យារពេលដើម្បីដាក់សារណាដ៏មានសារៈសំខាន់បន្ថែមទៅលើបណ្តឹងឧទ្ធរណ៍)។

[34] សូមមើល កថាខ័ណ្ឌ ៩ ខាងលើ ។

ច្រើន ត្រូវបានប្រគល់មុខងារឲ្យដោះស្រាយឲ្យបានដាច់ស្រេចចំពោះបញ្ហាពាក់ព័ន្ធទៅនឹងការឃុំខ្លួនបណ្ដោះអាសន្ន ។ ទីពីរ បេសកកម្មរបស់ អ.វ.ត.ក ក្នុងការនាំខ្លួនមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យមកជំនុំជម្រះទោសបាននិយាយថា គឺអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពានទៅលើច្បាប់មនុស្សធម៌អន្តរជាតិ អាចនឹងត្រូវបានគំរាមកំហែង ប្រសិនបើភាគីទាំងអស់មិនត្រូវបានធានាពី"ភាពច្បាស់លាស់ និងភាពអាចព្យាករបាន នៅក្នុងការអនុវត្តច្បាប់ដែលនៅជាធរមាន"[35]។ ចុងបញ្ចប់ សិទ្ធិប្ដឹងឧទ្ធរណ៍ (ជាផ្នែកមួយនៃសិទ្ធិក្នុងការទទួលបានការកាត់ក្ដីប្រកបដោយយុត្តិធម៌) "និងផ្ដល់ឲ្យមានការលើកស្ទួយដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការប្រព្រឹត្តមកលើរឿងក្ដីបែបនេះឲ្យបានដូចៗគ្នា[36]។ អាស្រ័យហេតុនេះ មូលហេតុនៃការចេញសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះគួរចងកាតព្វកិច្ចទៅលើ ក.ស.ច.ស ជាពិសេសសេចក្ដីសម្រេច អៀង នេះតែម្ដង។

## C. ការឃុំឃាំងឲ្យនៅដាច់ដោយឡែកពីគ្នាមិនជាការចាំបាច់

16. ក្នុងខណៈដែលមេធាវីការពារក្ដីទទួលយល់ព្រមថា ការទប់ស្កាត់ការឃុបឃិតគ្នា គឺជាផលប្រយោជន៍នៃការស៊ើបអង្កេតស្របច្បាប់ នោះដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួនមិនបានចង្អុលបង្ហាញឲ្យបានច្បាស់*ថាតើ*ការដាក់កំហិតមិនឲ្យទាក់ទងគ្នាទាំងស្រុងក្នុងចំណោមជនត្រូវចោទទាំងឡាយ ជាវិធានការចាំបាច់ដើម្បីការពារផលប្រយោជន៍នោះយ៉ាងដូចម្ដេចដែរ[37] ។ សនិទានភាពពិសេសមួយនៃសេចក្ដីសម្រេច អៀង គឺដោយសារថា លោក និងអ្នកស្រី អៀង មានពេលវេលាជាងសាមសិបឆ្នាំកន្លងទៅនេះ "ដើម្បីពិភាក្សាអំពីបញ្ហាទាំងឡាយដែលពាក់ព័ន្ធទៅនឹងការចោទប្រកាន់របស់ [អ.វ.ត.ក]" នោះការកំហិត ជំនួបគ្នាជាបន្តទៅទៀតរវាងពួកគាត់ មិនមែនជាការការពារផលប្រយោជន៍នៃការស៊ើបអង្កេតនោះទេ[38]។ ហេតុផល នេះអនុវត្តដោយមានសក្ដានុពលស្មើគ្នាចំពោះជនត្រូវចោទដទៃទៀត រួមមាន លោក នួន ជា ផងដែរ ដែលអ្នកទាំងអស់នេះមាន

---

[35] សាលដីកា Aleksovski កថាខ័ណ្ឌ ១១៣ ។

[36] សាលដីកា Aleksovski កថាខ័ណ្ឌ ១១៣ ។

[37] *សូមមើល* សេចក្ដីសម្រេច អៀង កថាខ័ណ្ឌ ១៨ ។

[38] សេចក្ដីសម្រេច អៀង កថាខ័ណ្ឌ ១៩-២០ ។

ឱកាសយ៉ាងច្រើនក្នុងអំឡុងពេលជាងបីទសវត្សកន្លងទៅដើម្បី ពិភាក្សាគ្នាដោយសេរីទៅលើបញ្ហាដូចគ្នានឹងលោក និង អ្នកស្រី អៀង[39] ដែរ ។

17. បន្ថែមលើនេះទៅទៀត ចាប់តាំងពីពេលដែលខ្មែរក្រហមបាក់បែកគ្នាជាផ្លូវការនៅក្នុងឆ្នាំ ១៩៩៦ មក ជនត្រូវចោទម្នាក់ៗ ត្រូវបាន "សម្ភាសន៍" ដោយអ្នកសារព័ត៌មាន (និងអ្នកផ្សេងទៀត) ទាក់ទិននឹងតួនាទី និងសកម្មភាពផ្សេងៗរបស់គេនៅចន្លោះឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ទោះបីជាពួកគេដឹងយ៉ាងច្បាស់ថា ការស៊ើបអង្កេតផ្នែកព្រហ្មទណ្ឌពិតជានឹងកើតឡើងដ៏ដោយ ។ ការលើកឡើងថា ជនត្រូវចោទអាចប៉ុនប៉ងប្រឌិតសាច់រឿងដែលផ្តល់ប្រយោជន៍ឱ្យគ្នាទៅវិញទៅមកដោយការដឹងថាសេចក្តីថ្លែងមុនៗបែបនេះ គឺជាផ្នែកមួយនៃសំណុំរឿងនោះ មិនអាចគួរឱ្យជឿបានទេ ។ តាមពិតទៅ *ពុំមានភស្តុតាង*បញ្ជាក់ថា មានអ្នកណាម្នាក់ក្នុងចំណោមពួកគេធ្លាប់មានចេតនាធ្វើបែបនេះនោះទេ ។

18. ក.ស.ច.ស មានការព្រួយបារម្ភថា ប្រសិនបើត្រូវបានអនុញ្ញាតឱ្យជួបគ្នា នោះជនត្រូវចោទអាចព្រមព្រៀងគ្នាប្រើប្រាស់"បណ្តាញអូសទាញ"[40]របស់ពួកគេដើម្បីដាក់សម្ពាធទៅលើសាក្សីសំខាន់ៗ កង្វល់បែបនេះពិតត្រូវបានបន្ធូរបន្ថយមកវិញដោយអង្គហេតុដែលថា ជនត្រូវចោទទាំងអស់ត្រូវបានឃុំខ្លួន និងមិនត្រូវបានអនុញ្ញាតឱ្យប្រាស្រ័យទាក់ទងជាមួយភពខាងក្រៅនោះទេ។ ដូចបានលើកឡើងខាងលើ *ពុំមានភស្តុតាង*ណាមួយដែលបញ្ជាក់ថា បណ្តាញបែបនេះកើតមាន ឬថាជនត្រូវចោទណាម្នាក់ធ្លាប់មានចេតនាប្រើប្រាស់ឥទ្ធិពល ដើម្បីដាក់ការគាបសង្កត់ទៅលើសាក្សីទាំងឡាយនៅក្នុងរឿងក្តីនេះទេ។ អាស្រ័យហេតុនេះ ក.ស.ច.ស ខកខានមិនបានបង្ហាញឱ្យឃើញថាការឃុំឃាំងឱ្យនៅដាច់ដោយឡែកគឺជាវិធានការចាំបាច់ ដូចដែលខ្លួនត្រូវតែបង្ហាញនោះឡើយ។

## D. ការឃុំឃាំងឱ្យនៅដាច់ដោយឡែកពីគ្នាពុំមានសមាមាត្រនោះទេ

19. ដីកាសម្រេចលើកខណ្ឌនៃការឃុំខ្លួនពុំបានពិនិត្យ*ថាតើ*ការឃុំឃាំងឱ្យនៅដាច់ដោយឡែក មានសមាមាត្រទៅនឹងគោលបំណងដែលបានលើកឡើងថា ដើម្បីចៀសវាងការឃុបឃិតគ្នាក្នុងចំណោមជនត្រូវចោទ ដោយរបៀបណានោះទេ។ សនិទានភាពបន្ថែមមួយទៀតនៃសេចក្តីសម្រេច អៀង គឺថា "អំឡុងពេលដ៏យូរលង់អង្វែង" នៃការឃុំខ្លួនឱ្យនៅដាច់ដោយឡែក "ដោយពុំមានការផ្តល់យុត្តិ

[39] ទំនាក់ទំនងជាប្តីប្រពន្ធរបស់លោក និង អ្នកស្រី អៀង ខណៈប្រហែលជាការពង្រឹងដល់ទឡ្ហីករណ៍ជាមូលដ្ឋាន ទាក់ទិននឹងស្ថានភាព ពិសេសរបស់ពួកគាត់ មិនបានធ្វើឱ្យអន់ថយ ដោយមធ្យោបាយណាមួយ ដល់ការអនុវត្តរបស់ខ្លួនចំពោះរឿងក្តីរបស់លោក នួន ជា និងអ្នកផ្សេងទៀតនោះទេ ។

[40] ដីកា កថាខណ្ឌ ៤ ។

កម្មសមស្រប បានធ្វើឱ្យប៉ះពាល់[យ៉ាងខ្លាំង] ដល់សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការប្រព្រឹត្តមកលើខ្លួនដោយមនុស្សធម៌។ ហេតុដូច្នេះ វិធានការនេះត្រូវបញ្ឈប់ជាដាច់ខាត”[41] យោងតាមអង្គបុរេជំនុំជម្រះ បញ្ហាមួយផ្សេងទៀត គឺ ក.ស.ច.ស ខកខានមិនបានពិចារណាពី “ការជាប់ទាក់ទិននៃសេចក្តីសម្រេច របស់ខ្លួនដែលនាំឱ្យមានការឃុំឃាំងដាច់ដោយឡែកពីគ្នាតាម*ព្រឹត្តិហេតុ*”[42]។

20. ជាថ្មីម្តងទៀត ហេតុផលដដែលនេះអនុវត្តដូចគ្នាទៅលើលោក នួន ជា និងជនត្រូវចោទដទៃទៀតដែលម្នាក់ៗទទួលបានសិទ្ធិឱ្យគេប្រព្រឹត្តមកលើខ្លួនដោយមនុស្សធម៌ និងមិនមែនជាកម្មវត្ថុនៃការឃុំឃាំងឱ្យនៅដាច់ដោយឡែកតាមព្រឹត្តិហេតុរយៈពេលដ៏យូរនោះទេ។ វាជាការពិតហើយដែលលោក នួន ជា ត្រូវ“បានអនុញ្ញាត”ឱ្យទទួលបាននូវការមកសួរសុខទុក្ខពីសំណាក់សមាជិកក្រុមគ្រួសារដែលជិតដិត[43]។ ប៉ុន្តែ ក្នុងតថភាពពិត ដោយសារចម្ងាយឆ្ងាយ និងស្ថានភាពផ្លូវលំបាកពីប៉ៃលិនមកភ្នំពេញ ក៏ដូចជា សោហ៊ុយធ្វើដំណើរដែលជាប់ពាក់ព័ន្ធ លោក នួន ជា បានជួបក្រុមគ្រួសាររបស់គាត់ប្រហែលជាម្តងក្នុងរយៈពេលប្រាំមួយសប្តាហ៍។ ហើយជាការពិត នៅពេលគាត់មានទំនាក់ទំនងជាទៀតទាត់ ជាមួយសមាជិកក្រុមការពារក្តីរបស់គាត់ ក៏ដូចជាបុគ្គលិករបស់មន្ទីរឃុំឃាំង[44] ការសន្មត់ទុកជាមុនថាគ្មានទោសបានផ្តល់សិទ្ធិឱ្យលោក នួន ជា ទទួលបាននូវជីវិតឯកជនលើសពីការមកសួរសុខទុក្ខ ស្របច្បាប់ជាទម្លាប់ និងការជួបប្រាស្រ័យទាក់ទងជាមួយអ្នកជាប់ឃុំរបស់គាត់។ សៀវភៅសារព័ត៌មាន និង ទូរទស្សន៍មិនអាចជំនួសឱ្យការប្រាស្រ័យទាក់ទងជាទៀងទាត់របស់មនុស្សដែលមិនមែនជាអ្នកវិជ្ជាជីវៈ បាននោះទេ។

21. ការវិភាគទៅលើសមាមាត្រភាពតម្រូវឱ្យមានការអនុវត្តប្រកបដោយតុល្យភាពល្អិតល្អន់មួយ[45] ។ ប៉ុន្តែ ជំនួសឱ្យការណែនាំយ៉ាងច្បាស់ពីអង្គបុរេជំនុំជម្រះដើម្បីចៀសវាងការដាក់វិធានការដែលនាំឱ្យមានការឃុំខ្លួនដាច់ដោយឡែកពីគ្នានោះ ក.ស.ច.ស ហាក់ដូចជាមិនបានពិចារណាលើមធ្យោបាយណាមួយដែលបន្ធូរបន្ថយដល់ការប៉ះពាល់ដោយការឃុំឃាំងឱ្យនៅដាច់ដោយឡែកពីគ្នា ដែលបានអនុវត្តនោះទេ (ដូចជា ការជួបសួរសុខទុក្ខក្នុងចំណោមជនត្រូវចោទឱ្យបានញឹកញាប់ដោយមាន

---

[41] ដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួន កថាខ័ណ្ឌ ៤ ។

[42] សេចក្តីសម្រេច អៀង កថាខ័ណ្ឌ ១៨ ។

[43] ដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួន កថាខ័ណ្ឌ ៨ ។

[44] ដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួន កថាខ័ណ្ឌ ៨ ។

[45] *សូមមើល* កថាខ័ណ្ឌ ១១ ខាងលើ ។

ការត្រួតពិនិត្យ)។ ជាការពិតណាស់ ក.ស.ច.ស អាចមានលទ្ធភាពក្នុងការស្វែងរកតុល្យភាព ប្រកបដោយសមធម៌ រវាងផលប្រយោជន៍នៃការស៊ើបអង្កេត និងសិទ្ធិរបស់ជនត្រូវចោទ។

## E. ដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួនបានបំផ្លើសពិតៗពីការជាប់ទាក់ទិននៃយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបដែលបានលើកឡើង

### 1. ហានិភ័យនៃការឃុបឃិតគ្នាគួរតែត្រូវបានបង្ហាញដោយភស្តុតាងជាក់ស្តែង

22. ដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួនបញ្ជាក់យ៉ាងច្បាស់ថា យោងតាមករណីយុត្តិសាស្ត្រនៅតុលាការសិទ្ធិមនុស្សអឺរ៉ុបៈ "គេមិនអាចជំទាស់តវ៉ាថា ការឃុំខ្លួនបណ្តោះអាសន្ន និងស្ថានភាពនៃការឃុំខ្លួន ដែលជាប់ពាក់ព័ន្ធ ត្រូវតែផ្តល់យុត្តិកម្មដោយការបង្ហាញនូវអំពើជាក់លាក់ តែផ្ទុយទៅវិញ មានធាតុតែមួយគត់ដែលត្រូវយកមកពិចារណាគឺការប៉ាន់ប្រមាណពីហានិភ័យ"[46]។ តែទោះជាយ៉ាងនេះក្តី ការពិនិត្យឡើងវិញឲ្យបានហ្មត់ចត់នៃករណីដែលបានលើកឡើង[47] បង្ហាញពីជំហរកាន់តែស៊ីជម្រៅជាងសំណើដែលដាក់ជូនដោយ ក.ស.ច.ស។ អាស្រ័យហេតុនេះ ការវិភាគលំអិតខ្លះៗពីយុត្តិសាស្ត្រ គឺជា ការបំភ្លឺផ្លូវមួយ។

---

[46] ដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួន កថាខ័ណ្ឌ ៣ ។

[47] ដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួន យោងទៅលើករណីចំនួនប្រាំបីនៅតុលាការសិទ្ធិមនុស្សអឺរ៉ុប ដើម្បីគាំទ្រដល់សំណើនេះ: *Gorski* តទល់នឹង ប្រទេសប៉ូឡូញ តុលាការសិទ្ធិមនុស្សអឺរ៉ុប "សាលក្រម" ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៥ (ហៅថា "សេចក្តីសម្រេច *Gorski*"), *Celejewski* តទល់នឹងប្រទេសប៉ូឡូញ តុលាការសិទ្ធិមនុស្សអឺរ៉ុប "សាលក្រម" ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៦ (ហៅថា"សេចក្តីសម្រេច *Celejewski*"), *Bak* តទល់នឹងប្រទេសប៉ូឡូញ តុលាការសិទ្ធិមនុស្សអឺរ៉ុប "សាលក្រម" ចុះថ្ងៃទី16 ខែមករា ឆ្នាំ២០០៧ (ហៅថា "សេចក្តីសម្រេច *Bak*"), *Laskiewicz* តទល់នឹងប្រទេសប៉ូឡូញ តុលាការសិទ្ធិមនុស្សអឺរ៉ុប "សាលក្រម" ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៨ (ហៅថា "សេចក្តីសម្រេច *Laskiewicz*"), *Bernard* តទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប "សាលក្រម" ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៦ (ហៅថា "សេចក្តីសម្រេច *Bernard*"), "); *Kemmache* តទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប "សាលក្រម" ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩១ (ហៅថា "សេចក្តីសម្រេចលើករណី *Kemmache*"), *W.* តទល់នឹងប្រទេសស្វីស តុលាការសិទ្ធិមនុស្សអឺរ៉ុប "សាលក្រម" ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៣ (ហៅថា "សេចក្តីសម្រេចលើករណី *W.*"), *Muller.* តទល់នឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប "សាលក្រម" ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៩៧ (ហៅថា "សេចក្តីសម្រេចលើករណី *W.*") ។

23. ក្នុងខណៈ ដែលតុលាការសិទ្ធិមនុស្សអឺរ៉ុបមិនបានដោះស្រាយឱ្យបានគ្រប់ជ្រុងជ្រោយនូវបញ្ហាពិស្ដារ ដែលបានលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍នេះករណីយុត្តិសាស្ត្ររបស់តុលាការនេះមិនទទួលស្គាល់ថា អំឡុងពេល *ឃុំខ្លួន*ដែលបានអូសបន្លាយ (មិនមែនជាការឃុំដាច់ដោយឡែកដូចនេះទេ) អាចត្រូវបានធ្វើ យុត្តិកម្មផ្នែកខ្លះនៅក្នុងរឿងក្ដីព្រហ្មទណ្ឌស្មុគស្មាញដែលមានជនល្មើសច្រើននាក់ ដោយមិនបានចង្អុលបង្ហាញពីហានិភ័យនៃការឃុបឃិតគ្នា ឬការជ្រៀតជ្រែកមិនសមស្របទៅលើលទ្ធផលនៃដំណើរការ នីតិវិធី។ សំណើរតែមួយនេះត្រូវបានគាំទ្រដោយរឿងក្ដីមួយចំនួនទាក់ទិនទៅនឹងការអនុវត្តមាត្រា ២៥៨(២)នៃក្រមនីតិវិធីព្រហ្មទណ្ឌប៉ូឡូញដែលទទួលស្គាល់ "ការសន្មត់ទៅចំពោះប្រសិទ្ធិភាពដែលថា ភវនីយភាពនៃទណ្ឌកម្មដ៏ធ្ងន់ធ្ងរមួយដែលកំពុងអនុវត្តមកលើចុងចោទ អាចនាំឱ្យគេបង្កាំងស្ទះដល់ ដំណើរការនីតិវិធី"[48]។

24. នៅក្នុងសេចក្ដីសម្រេច Gorski សាលាឧទ្ធរណ៍នៃប្រទេសប៉ូឡូញបានយល់ថា "ហានិភ័យនៃការរត់គេចខ្លួន ឬការជ្រៀតជ្រែកមកលើសាក្សីដែលបានកើតឡើងនៅក្នុងករណីបច្ចុប្បន្ននេះ មិនចាំបាច់គាំទ្រ ដោយភស្ដុតាងជាក់ស្ដែងផ្សេងទៀតនោះទេ ប៉ុន្តែ វាបានមកពីការសន្មត់ខាងលើ[49] ទោះបីជាតុលាការសិទ្ធិមនុស្សអឺរ៉ុបបានដាក់ទណ្ឌកម្មទៅលើការរកឃើញនេះ ថាជាបញ្ហាទូទៅមួយក៏ដោយ ក៏ការដែលបានធ្វើបែបនេះគឺជាវិធានការមួយនៃការត្រួតពិនិត្យឡើងវិញ:

> តុលាការពិចារណាថា ហានិភ័យដែលបានលើកឡើងជាទូទៅកើតចេញពីសារជាតិនៃសកម្មភាពឧក្រិដ្ឋរបស់ចុងចោទអាចត្រូវបានទទួលយកជាមូលដ្ឋានដើម្បីឃុំខ្លួនរូបគេនៅដំណាក់កាលដំបូងនៃដំណើរការ នីតិវិធី។ ទោះជាយ៉ាងណាក៏ដោយ ក្នុងការអវត្តមានកត្តាផ្សេងទៀតដែលអាចបង្ហាញថា ហានិភ័យគឺអាស្រ័យទៅលើការពិតដែលបានកើតឡើង នោះតុលាការមិនអាចទទួលយកមូលហេតុនោះថាជាយុត្តិកម្មដើម្បីឃុំខ្លួនចុងចោទសម្រាប់អំឡុងពេលពាក់ព័ន្ធទាំងស្រុងនោះទេ[50]។

សេចក្ដីសម្រេចរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបចំនួនបីជាបន្តបន្ទាប់ បានបញ្ជាក់ពីការគាំទ្រដំបូងដល់សេចក្ដីសម្រេច Gorski ដែលមានពាក្យពេចន៍ស្រដៀងគ្នា[51]។ ពាក្យពេចន៍ដែលមានអត្ថន័យ

---

[48] សេចក្ដីសម្រេច Gorski កថាខ័ណ្ឌ ២៤ ។

[49] សេចក្ដីសម្រេច Gorski កថាខ័ណ្ឌ ២៤ ។

[50] សេចក្ដីសម្រេច Gorski កថាខ័ណ្ឌ ៥៨ ។

[51] សូមមើលសេចក្ដីសម្រេច Celejewski កថាខ័ណ្ឌ ៣៧ (សំអាងទៅលើសេចក្ដីសម្រេច Gorski)។ សេចក្ដីសម្រេច Bak កថាខ័ណ្ឌ ៥៧ (សំអាងទៅលើសេចក្ដីសម្រេច Celejewski)។ សេចក្ដីសម្រេច Laskiewicz កថាខ័ណ្ឌ ៥៩ (សំអាងទៅលើសេចក្ដីសម្រេច Gorski និងសេចក្ដីសម្រេច Celejewski)។

ច្បាស់លាស់នៅក្នុងសេចក្តីសម្រេច Celejewski បានគូសបញ្ជាក់ថា “ដោយពេលវេលាបានកន្លងផុតទៅ មូលហេតុដំបូង [...] កាន់តែមានការពាក់ព័ន្ធតិចទៅៗ ហើយ [តុលាការយុត្តិសាស្ត្រ] គួរតែសំអាងទៅលើមូលហេតុផ្សេងទៀតដែល “ពាក់ព័ន្ធ” និង “គ្រប់គ្រាន់” ដើម្បីធ្វើយុត្តិកម្មលើ [វិធានការទាំងនេះ][52] និងបានកត់សម្គាល់ថា យុត្តិសាស្ត្រ ដូចគ្នានេះមានកាតព្វកិច្ចពិចារណាលើ “វិធានការជាជម្រើស”[53]។ ថ្វីបើការយល់ព្រមសាកល្បងរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបចំពោះ (ការសន្មត់របស់ប៉ូឡូញ “Polish Presumption”) ហានិភ័យនៃការឃុបឃិតគ្នា ត្រូវបានគាំទ្រដោយ*ភស្តុតាងជាក់ស្តែង* នៅក្នុងករណីចំនួនពីរក្នុងចំណោមករណីបួន[54]។ ចំនុចនេះមិនបានលើកឡើងនៅក្នុងដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួននោះទេ ។

25. អ្វីដែលមិនមាននៅក្នុងការវិភាគរបស់ ក.ស.ច.ស គឺថាករណីបួនផ្សេងទៀតក្នុងចំណោមករណីប្រាំបីរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ECHR ដែលបានលើកសំអាង គាំទ្រយ៉ាងច្បាស់លើវិធីសាស្ត្ររបស់តុលាការ ICC ដែលតម្រូវ “ភស្តុតាងជុំកំភួន” អំពីហានិភ័យនៃ“ការត្រូវរូវគ្នា”[55]។ ជាការពិត សេចក្តីសម្រេចករណី Bernard (សម្រេចក្រោយករណី Gorski) បានបដិសេធលើការពឹងផ្អែករបស់តុលាការបារាំងស្តីពីហានិភ័យនៃការត្រូវរូវគ្នា ដោយមូលហេតុថា “អង្គហេតុ” ដែលបានបង្ហាញ ពុំមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្កើតហានិភ័យនោះទេ ។

---

[52] សេចក្តីសម្រេច Celejewski កថាខ័ណ្ឌ ៣៨ ។

[53] សេចក្តីសម្រេច Celejewski កថាខ័ណ្ឌ ៣៩ ។

[54] *សូមមើល*សេចក្តីសម្រេច Gorski កថាខ័ណ្ឌ ៤៤ (ដែលជនសង្ស័យម្នាក់ក្នុងចំណោមជនសង្ស័យជាច្រើន បានប៉ុនប៉ងប្រើឥទ្ធិពលទៅលើការផ្តល់សក្ខីកម្មរបស់ សាក្សីមុនពេលចាប់ខ្លួនរូបគេ) និងសេចក្តីសម្រេច Bak កថាខ័ណ្ឌ ១៩ (ដែលជនជាប់ចោទម្នាក់ ក្នុងចំណោមជនជាប់ចោទជាច្រើន បានកែប្រែចម្លើយរបស់គេយ៉ាងច្រើននៅក្នុងពេលសវនាការ)។

[55] សូមមើលសេចក្តីសម្រេច Bernard កថាខណ្ឌ ៤២ ( “អង្គហេតុ”ដែលបានបង្ហាញ ពុំមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្កើតហានិភ័យធ្ងន់ធ្ងរនៃការឃុបឃិតគ្នា និង មូលហេតុត្រូវបានបដិសេធ) ។ សេចក្តីសម្រេច Kemmache កថាខណ្ឌ១១ ២៦ ២៨ និង ៥៤ (ការឃុំខ្លួនបណ្តោះអាសន្នបន្តរហូតដល់ពេលបញ្ចប់នៃការស៊ើបអង្កេតត្រូវបានធ្វើយុត្តិកម្ម នៅពេលដែលអ្នកសុំបង់ប្រាក់ឱ្យសហជនជាប់ចោទ ដើម្បីផ្តល់សក្ខីកម្មក្លែងក្លាយ ហើយចំនុចនេះគាំទ្រដល់ការភ័យខ្លាចចំពោះបន្តដាក់សំពាធទៅលើសាក្សី) ។ សូមមើលផងដែរនូវសេចក្តីសម្រេចករណី W. កថាខណ្ឌ ៩ និង ៣៦ (អាជ្ញាធរជាតិមានអំណាចក្លែងក្លាយគណនីធនាគារក្រុមហ៊ុនរបស់អ្នកសុំ ក្នុងគោលបំណងរាំងដល់ការស៊ើបអង្កេត ជាយុត្តិកម្មសម្រាប់ការប្រើប្រាស់ហានិភ័យនៃការឃុបឃិតគ្នា ធ្វើជាទម្លើករណីសម្រាប់ការឃុំខ្លួន) ។ សេចក្តីសម្រេច Muller កថាខណ្ឌ ២៤ និង៤០ (ការឃុំខ្លួនបណ្តោះអាសន្នបន្តរហូតដល់ពេលបញ្ចប់នៃការស៊ើបអង្កេតត្រូវបានធ្វើយុត្តិកម្ម នៅពេលមានហានិភ័យនៃឃុបឃិតគ្នារវាងសហចារីដែលបានគាំទ្រដោយអង្គហេតុដែលថា សហជនជាប់ចោទទាំងពីរបានព្យាយាមជាច្រើន ដើម្បីដាក់បន្ទុកទោសលើជនសមគំនិត និង បក្សពួករបស់ខ្លួនដែលចោទប្រកាន់ពីបទសមគំនិតប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ) ។

26. សេចក្តីសម្រេចពិតប្រាកដរបស់ករណីទាំងប្រាំបី ដែលបានសំអាងនៅក្នុងដីកាដើម្បីគាំទ្រដល់ទឡ្ហីករណ៍ខាងលើ គឺមិនសមស្របទាំងខ្លឹមសារ និង ទម្ងន់ពាក្យពេចន៍នៃការពិពណ៌នារបស់សហចៅក្រមស៊ើបអង្កេតនោះទេ ។ បញ្ហាមួយផ្សេងទៀត គឺការវិភាគរបស់ការិយាល័យសហចៅក្រមទៅលើសេចក្តីសម្រេច ដោយ ICC តែប៉ុណ្ណោះ[56] ។ ការពិតទៅ វាមិនមែនជាសេចក្តីសម្រេច "ដាច់តែឯង" នោះទេ តាមពិតសនិទាននៃសេចក្តីសម្រេច Katanga គឺគាំទ្រដោយសេចកក្តីសម្រេចលើករណីប្រាំមួយក្នុងចំណោមករណីទាំងប្រាំបីរបស់ ECHR ដែលបានលើកសំអាងនៅក្នុងដីកា ព្រមជាមួយការអនុវត្តនៅ ICTY, ICTR និងតុលាការពិសេសសៀរ៉ាឡេអូន ។ សូមកត់សំគាល់ថា ពុំមានតុលាការណាមួយក្នុងចំណោមតុលាការខាងលើដោះស្រាយនូវរឿងក្តីស្មុកស្មាញដែលជាប់ពាក់ព័ន្ធជាមួយជនជាប់ចោទច្រើននាក់ បានទទួលស្គាល់នូវការសន្មត់នៃការត្រូវរ៉ូវគ្នាក្នុងចំណោមសហជនជាប់ចោទ ដែលកំពុងជាប់ឃុំនោះឡើយ ។ ដីកាបានខកខានបង្កើតករណីមួយត្រឹមត្រូវដែលអាចឱ្យក.ស.ច.ស ងាកចេញពីវិធីសាស្រ្តអន្តរជាតិ។

27. ដោយពិចារណាលើ(i) អវត្តមាននៃការសន្មតជាមុននៃការត្រូវរ៉ូវគ្នានៅ អ.វ.ត.ក[57] (ii) ការសំអាងលើកមុនដោយអង្គជំនុំជម្រះនេះទៅលើសេចក្តីសម្រេច Katanga (សូម្បីតែលើចំនុចខុសគ្នានៃច្បាប់ និង (ii) កត្តាដែលថាសេចក្តីសម្រេចភាគច្រើនរបស់ ECHR ដែលបានសំអាង ព្រមទាំងសេចក្តីសម្រេចរបស់តុលាការអន្តរជាតិមួយចំនួនទៀត គាំទ្រនូវដំណោះស្រាយយ៉ាងប្រយ័ត្នប្រយែង

[56] ដីកា កថាខណ្ឌ ៣ ("សេចក្តីសម្រេចដាច់តែឯងដែលចេញដោយអង្គជំនុំជម្រះសាលាដំបូងរបស់ ICC នៅក្នុង [សេចក្តីសម្រេច Katanga] មិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីលើកសំអាងហេតុផលថា សេចក្តីសម្រេចរបស់ ECHR ប្រហាក់ប្រហែលនឹងករណីបច្ចុប្បន្ននេះ" ។

[57] ចំពោះ "ភស្តុតាងជាដុំកំភួន" អំពីហានិភ័យនៃការត្រូវរ៉ូវគ្នា ក.ស.ច.ស បានដាក់ជំនួសនូវសេចក្តីពន្យល់ post facto ដែលមិនសូវច្បាស់នៅក្នុងដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នរបស់ខ្លួន: ដោយសារតែសេចក្តីសម្រេចនោះត្រូវបានធ្វើយុត្តិកម្មជាផ្នែកមួយនៃសេចក្តីត្រូវការទូទៅដើម្បីទប់ស្កាត់លោក នួន ជា ពីការដាក់សំពាធទៅលើសាក្សី និង ជនរងគ្រោះ "តែមិនបានបញ្ជាក់ថាជនជាប់ឃុំមិនអាចប្រាស្រ័យទាក់ទងជាមួយជនជាប់ឃុំដទៃទៀត ដោយតែការត្រូវរ៉ូវគ្នាអាចសម្របសម្រួលការដាក់គាបសង្កត់ដោយពិចារណាលើឥទ្ធិពលរបស់សហជនត្រូវចោទនីមួយៗ" ដីកា កថាខណ្ឌទី ៤ ។ហានិភ័យនេះត្រូវបានពិចារណាថាមានកំរិតខ្ពស់ អំណោះអំណាងបន្តថា លោក នួន ជា និង ជនត្រូវចោទដទៃទៀតបានត្រូវបានចាប់ខ្លួន និង ចោទប្រកាន់ ហើយ អាចមើលសំណុំរឿង "ដែលមិនត្រឹមតែបង្ហាញពីកម្រិតនៃការទទួលខុសត្រូវបុគ្គលលើបទចោទប្រកាន់ចំពោះគេម្នាក់ៗ ប៉ុន្តែជូនដំណឹងឱ្យពួកគេអំពីទិសដៅ និង ខ្លឹមសារនៃកិច្ចស៊ើបអង្កេតផងដែរ" ។ ដីកា កថាខណ្ឌ ៥។ ប៉ន្តែការពន្យល់បែបនេះ ផ្អែកទៅលើតែការប្រមើលមើលតែប៉ុណ្ណោះ គឺមិនមានអ្វីឱ្យលើសពីការប៉ុនប៉ងបោកបញ្ឆោតដើម្បីការសន្មតផ្លូវច្បាប់នៃការត្រូវរ៉ូវគ្នារវាងជនត្រូវចោទនៅអង្គជំនុំជម្រះវិសាមញ្ញ ដូចជាករណីដែលត្រូវបានទទួលស្គាល់ដោយសាលាឧទ្ធរណ៍ប៉ូឡូញ ។

ចំពោះបញ្ហា ហើយមេធាវីសូមស្នើថា សេចក្តីសម្រេចរបស់ ក.ស.ច.ស ត្រូវតែបដិសេធ ដើម្បីបំពេញបំណងប្រាថ្នានៃសេចក្តីសម្រេចរបស់ **ICC** ដែលតម្រូវ"ភស្តុតាងជុំកំភួន" នៃការត្រូវរូវគ្នា ដើម្បីធ្វើយុត្តិកម្មលើវិធានការណ៍តឹងរឹងខ្លួចជាការដាក់ឃុំឲ្យនៅដាច់ដោយឡែកពីគ្នា ។

## ២. ពុំមានហានិភ័យនៃការបន្តការចូលរួមនៅក្នុងសកម្មភាពព្រហ្មទណ្ឌដោយខ្មែរក្រហម ឬ ការគំរាមកំហែងសន្តិសុខ

28. ដើម្បីគាំទ្រដល់ទស្សនៈរបស់ខ្លួន ការដាក់ឃុំឲ្យនៅដាច់ដោយឡែកពីគ្នា មិនបានរំលោភទៅលើមាត្រា ៣ និង/ឬ មាត្រា ៨ នៃអនុសញ្ញាអឺរ៉ុបទេ ។ក.ស.ច.ស សំអាងលើយុត្តិសាស្ត្រពីរដោយឡែកពីគ្នារបស់ ECHR ដែលយុត្តិសាស្ត្រទីមួយពាក់ព័ន្ធជាមួយអង្គការភេរវកម្ម[58] និងយុត្តិសាស្ត្រទីពីរពាក់ព័ន្ធអង្គការ Mafia[59]។ ប៉ុន្តែ ករណីដែលបានសំអាង គឺមានមិនហេតុផលខាងអង្គហេតុ ហើយអាស្រ័យហេតុនេះ វាមិនបានផ្តល់ការគាំទ្រដល់សេចក្តីសម្រេចរបស់ ក.ស.ច.ស នោះទេ ការព្រួយបារម្ភរបស់អាជ្ញាឃុំខ្លួន គឺការទប់ស្កាត់នូវសកម្មភាពបទល្មើសបន្ថែម រួមទាំងអំពើហិង្សាដែលបង្កឡើងដោយការដោះលែងជនជាប់ឃុំ[60] ខណៈដែលខ្មែរក្រហមបានដួលរលំជាងរយៈពេល

[58] ករណី *Ensslin et al តទល់ជាមួយសាធារណៈសហព័ន្ធអាល្លឺម៉ង់*, គណៈសិទ្ធិមនុស្សអឺរ៉ុប "សេចក្តីសម្រេច ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៧៨ (ហៅថា"សេចក្តីសម្រេច **Ensslin**") ។ *ករណី Illascu តទល់ជាមួយ Moldova និង រុស្ស៊ី* ECHR " សេចក្តីសម្រេចចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៥ (ហៅថា "សេចក្តីសម្រេច Ocalan"), *ករណី **Ocalan** តទល់ជាមួយប្រទេសទួគី* ECHR "សេចក្តីសម្រេចចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០០៦ (ហៅថា "សេចក្តីសម្រេច Ramirez-Sanchez")

[59] *ករណី **Messina** តទល់ជាមួយប្រទេសអ៊ីតាលី* (No.2) ECHR សេចក្តីសម្រេចចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០០ (ហៅថា " សេចក្តីសម្រេច **Messina**") និង សេចក្តីសម្រេចដទៃទៀត (មានជាអាទសេចក្តីសម្រេច the Argenti, Cavallo និង Guidi) (ជារួមហៅថា "ករណី Mafia")។ ករណី Mafia ទាំងអស់ដោះស្រាយជាមួយការអនុវត្តមួយដែលហៅថា "Special Regime") នៅផ្នែក៤១ នៃច្បាប់គ្រប់គ្រងពន្ធនាគារអ៊ីតាលី ផ្តល់អំណាចដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដើម្បីព្យួរការអនុវត្តរបបពន្ធនាគារធម្មតា prison regime ទាំងមូល ឬ មួយផ្នែកចំពោះមូលហេតុសណ្តាប់ធ្នាប់សាធារណៈ និង សន្តិសុខ នៅក្នុងករណីដែលរបបពន្ធនាគារធម្មតាមិនបំពេញតាមលក្ខខណ្ឌតម្រូវ ។ វិធានការណ៍បែបនេះអាចអនុវត្តចំពោះតែអ្នកជាប់ឃុំដែលត្រូវចោទ ឬ ផ្តន្ទាទោសពីបទល្មើសចែងនៅក្នុងផ្នែក៤ នៃច្បាប់នេះ ដែលបញ្ចូលនូវបទល្មើសទាំងឡាយទាក់ទងនឹងសកម្មភាពរបស់ Mafia សូមមើលសេចក្តីសម្រេច **Messina** កថាខណ្ឌទី៤២ និងទី៤៣ ។

[60] សេចក្តីសម្រេច **Messina** កថាខណ្ឌ៤៦ ("[...] របបដែលចែងនៅក្នុងផ្នែក 41 *bis* ត្រូវបានបង្កើតឡើងដើម្បីកាត់ផ្តាច់ទំនាក់ទំនងរវាងអ្នកទោសពាក់ព័ន្ធ ជាមួយនឹងសកម្មភាពឧក្រិដ្ឋរបស់ពួកគេ ក្នុងគោលបំណងកាត់បន្ថយហានិភ័យដែលថាពួកគេនឹងបន្តទំនាក់ទំនងជាមួយអង្គការឧក្រិដ្ឋកម្ម [...] មុនណែនាំរបបពិសេសដល់សមាជិកជាប់ឃុំរបស់ Mafia អាចរក្សាការទំនាក់ទំនងជាមួយអង្គការឧឬកិដ្ឋកម្មរបស់ពួកគេបាន ដើម្បីផ្លាស់ប្តូរព័ត៌មានជាមួយអ្នកទោសផ្សេងទៀត និងពិភពខាងក្រៅ និងដើម្បីរៀបចំ និងប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរទាំងក្នុង និងខាងក្រៅពន្ធនាគារ [...]") ។ ទាំងសេចក្តីសម្រេច **Messina**, សេចក្តីសម្រេច

ជាង១០ឆ្នាំមកហើយ ហើយក៏ពុំមាននរណាម្នាក់អាចអះអាងប្រកបដោយការជឿទុកចិត្តថា រាល់ការប៉ុនប៉ងដោះលែងជនត្រូវចោទដោយមធ្យោបាយហិង្សា ត្រូវបានពិចារណាឡើយ ។ ការខកខានរបស់ ក.ស.ច.ស ដើម្បីទទួលស្គាល់នូវការខុសគ្នាយ៉ាងសំខាន់បែបនេះ គឺគ្រោះថ្នាក់ដល់សេចក្ដីសម្រេចរបស់ខ្លួន[61] ។ ក្នុងខណៈជាសំណើទូទៅ មេធាវីការពារទទួលថា (i) ការទាត់ចោលអ្នកជាប់ឃុំចេញពីសហាគមន៍ពន្ធនាគារទូទៅ មិនអាចចាត់ទុកជាការប្រព្រឹត្តបែបអមនុស្សធម៌ និង បន្ថោកបន្ទាបឡើយ[62] និង(ii)ការកម្រិតមួយចំនួនទៅលើសិទ្ធឯកជននិងគ្រួសារ អាចត្រូវបានតម្រូវដើម្បីថែរក្សាបូរណភាពនៃកិច្ចស៊ើបអង្កេតរបស់តុលាការ[63]។ យ៉ាងណាក៏ដោយ ដំហ៊ររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតទាក់ទងនឹងនឹងចំនុចទាំងពីរ គឺផ្អែកលើការសន្មតអង្គហេតុដែលពុំមានលក្ខណៈគ្រប់គ្រាន់[64] ហើយអាស្រ័យហេតុនេះ ត្រូវបដិសេធដោយអង្គបុរេជំនុំជម្រះ ។

### ៣. ការអនុវត្តយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបសិទ្ធិមនុស្សចំពោះករណីនេះ គឺមានដែនកំណត់

29. តុលាការអឺរ៉ុបសិទ្ធិមនុស្ស មានកាតព្វកិច្ចពិនិត្យឡើងវិញនូវសេចក្ដីសម្រេចនានារបស់តុលាការរដ្ឋជាសមាជិកសហគមន៍អឺរ៉ុប ក្នុងបំណងបង្កើត, ក្នុងចំណោមដទៃទៀត, បទដ្ឋានជាអប្បបរមានៃ

---

Ocalan ឬ សេចក្ដីសម្រេច Ramirez-Sanchez មិនបាននិយាយអ្វីសោះអំពីការត្រូវរូវគ្នា ដើម្បីបង្អាក់ដល់ដំណើរការនីតិវិធី (ប៉ុន្តែសេចក្ដីសម្រេចទាំងនោះបានហាមឃាត់ដល់ការប្រាស្រ័យទាក់ទងគ្នា "ដោយមូលហេតុសន្តិសុខ វិន័យ ឬការការពារ" ក្នុងករណីភេរវកម្ម ខណៈដែលអង្គការឧក្រិដ្ឋកម្មនៅមានសកម្មភាព និង បន្តប្រព្រឹត្តហិង្សាឧក្រិដ្ឋកម្ម) ។ សេចក្ដីសម្រេច Messina កថាខណ្ឌទី ៥ ទំព័រ១០៩ (សមាជិកនៃក្រុមអ្នកលែង (Baader-Meinhof Gang) ដែលជាប់ឃុំ បានប្រើអាវុធនៅពេលចាប់ខ្លួន RAF បានរៀបចំការវាយប្រដាប់អាវុធជាញឹកញាប់ ដើម្បីទាមទារឲ្យដោះលែងសមាជិករបស់ខ្លួន ។ មានការចង្អុលបង្ហាញថាពួកគេបានចូលរួមចំណែកចំពោះអំពើទាំងនោះ ហើយ Baader ខ្លួនឯងផ្ទាល់ធ្លាប់បានរត់គេចពីគុកដោយប្រើអាវុធ) ។ សេចក្ដីសម្រេច Ocalan កថាខណ្ឌ ១៩២ និង១៩៥ (ការឃុំខ្លួន Ocalan ត្រូវបានយុត្តិកម្មដោយមូលហេតុថា ក្នុងនាមជាមេដឹកនាំ PKK គាត់ត្រូវបានចាត់ទុកថាជាភេរវករដ៏គ្រោះថ្នាក់បំផុតនៅទួគី ។ ជីវិតរបស់គាត់ស្ថិតនៅក្នុងភាពគ្រោះថ្នាក់ ហើយរដ្ឋាភិបាលភ័យខ្លាចថាមិនអាចការពារជីវិតរបស់គាត់បាននៅក្នុងពន្ធនាគារធម្មតា ហើយមានការភ័យខ្លាចសមហេតុផលថា អ្នកគាំទ្ររបស់គាត់នឹងព្យាយាមជួយគាត់ឲ្យរត់គេចខ្លួន) ។ សេចក្ដីសម្រេច Ramirez-Sanchez កថាខណ្ឌ ១២៥ (នៅក្នុងករណីដែលត្រូវបានទទួលស្គាល់ថា ការឃុំខ្លួន "Carlos the Jackal" ដែលកាលពីពេលនោះ ពិភពលោកចាត់ទុកគាត់ជាមេភេរវករដ៏គ្រោះថ្នាក់ម្នាក់ គំរាមកំហែងដល់យ៉ាងធ្ងន់ធ្ងរដល់អាជ្ញាធរបារាំង) ។

[61] ជាការពិត ក.ស.ច.ស ធ្វេសប្រហែសក្នុងពិចារណាភាពស្រដៀងគ្នានៃអង្គហេតុរវាងករណីដែលបានសំអាង ជាមួយករណីបច្ចុប្បន្ន ។

[62] ដីកា កថាខណ្ឌទី ៧ ។

[63] ដីកា កថាខណ្ឌទី ១០ ។

[64] សូមមើលកថាខណ្ឌទី១៦ ដល់ទី២១ ខាងលើ ។

ការជម្រះក្តីដោយយុត្តិធម៌ ។ ដូច្នេះហើយ តម្លៃនៃសេចក្តីសម្រេចរបស់តុលាការនេះ មានដែនកំណត់ ពិសេសក្នុងករណីដែលតុលាការកំណត់ឱ្យមានការធានានូវដំណើរការត្រឹមត្រូវបន្ថែមលើសពីការធានាទាំងឡាយដែលតម្រូវដោយអនុសញ្ញាអឺរ៉ុប គឺមានលក្ខណៈសមរម្យ ។ ឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងរបស់ ICC បានកំណត់ថា វាជាការសមរម្យដើម្បីតម្រូវនូវ "ភស្តុតាងដុំកំភួន" អំពីការត្រូវរួមគ្នា មុនដាក់ចេញនូវវិធានការណ៍រឹតត្បិតការប្រាស្រ័យទាក់ទងគ្នាក្នុងចំណោមសហជនជាប់ចោទ[65] ។ បញ្ហាដែលថាតុលាការអឺរ៉ុបសិទ្ធិមនុស្សបានដាក់ទណ្ឌកម្មលើមាត្រា ២៥៨(២) នៃក្រមនីតិវិធីព្រហ្មទណ្ឌប៉ូឡូញ- ដែលត្រូវបានបកស្រាយដោយសាលាឧទ្ធរណ៍ប៉ូឡូញ ទោះបីជាមិនតម្រូវឱ្យមានការបកស្រាយបែបនេះក៏ដោយ- ដែលមិនបានបង្កអន្តរាយដល់វិធីសាស្ត្ររបស់ ICC នោះឡើយ ។ ជាការពិត គេមិនអាចនិយាយថា អ.វ.ត.ក ត្រូវបានរារាំងក្នុងការអនុម័តវិធីសាស្ត្ររបស់ ICC ដែរ ពីព្រោះបើធ្វើយ៉ាងដូច្នេះមែន វានឹងនឹងធ្វើឱ្យលើសបទដ្ឋានអប្បបរិមារបស់តុលាការអឺរ៉ុបសិទ្ធិមនុស្ស ។

## V. សេចក្តីសន្និដ្ឋាន

30. អាស្រ័យដោយមូលហេតុទាំងអស់ដូចមានបញ្ជាក់ជូននៅទីនេះ មេធាវីការពារស្នើដោយក្តីគោរពសុំអង្គបុរេជំនុំជម្រះប្រកាសមោឃៈភាពនូវការដាក់ឃុំដាច់ដោយឡែកពីគ្នា (របប) ហើយអនុញ្ញាតឱ្យលោក នួន ជា និង ជនត្រូវចោទផ្សេងទៀត ប្រាស្រ័យទាក់ទងគ្នាដោយកម្រិត ទៅតាមបំណងរបស់ពួកគេ ។

សូមអង្គបុរេជំនុំជម្រះទទួលបណ្តឹងឧទ្ធរណ៍នេះដោយក្តីគោរព ។

សហមេធាវីលោក នួន ជា

សុន អរុណ

Michiel PESTMAN

[65] សូមមើលសេចក្តីសម្រេច Katanga ។